ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
"ឈ្នះការទិញទំនិញដោយឥតគិតថ្លៃ រហូតដល់ ៥០០ ដុល្លារពីអ៊ីអនកាតនៅផ្សារទំនើបអ៊ីអនម៉ល"
បញ្ជាក្តី និងលក្ខខណ្ឌ

និយមន័យ៖

- ប្រូម៉ូសិន៖ សំដៅទៅលើការ "**ឈ្នះការទិញទំនិញដោយឥតគិតថ្លៃ រហូតដល់ ៥០០ ដុល្លារពីអ៊ីអនកាតនៅផ្សារទំនើបអ៊ីអនម៉ល**" ដែលរៀបចំដោយ អ៊ីអន អេសភីប៊ី ស្របតាមលក្ខខណ្ឌដែលបានកំណត់ នាពេលនេះ។
- អ៊ីអន អេសភីប៊ី៖ សំដៅទៅលើ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។
- ម្ចាស់កាតដែលមានសិទ្ធិ៖ សំដៅទៅលើម្ចាស់អ៊ីអនកាតទាំងអស់ (មិនរាប់បញ្ចូលបុគ្គលិករបស់អ៊ីអន អេសភីប៊ី និងបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនអ៊ីអន) ដែលមានអ៊ីអនកាត និងធ្វើការទូទាត់ក្នុងអំឡុងពេលប្រូម៉ូសិន លើកលែងតែម្ចាស់កាតដែលគណនីកាតត្រូវបានផ្អាក លុបចោល ឬបិទដោយហេតុផលណាមួយក្នុងអំឡុងពេលប្រូម៉ូសិន។
- ទីតាំងដែលមានសិទ្ធិ៖ សំដៅទៅលើ គ្រប់បណ្តាហាងទាំងអស់ក្នុង ផ្សារទំនើបអ៊ីអនម៉លភ្នំពេញ អ៊ីអនម៉លសែនសុខ អ៊ីអនម៉លមានជ័យ និងអ៊ីអនខេមបូឌា គ្រប់សាខា។
- អ្នកឈ្នះ៖សំដៅទៅលើម្ចាស់អ៊ីអនកាតដែលបំពេញតាមតម្រូវការទាំងអស់នៃលក្ខខណ្ឌទាំងនេះ នឹងត្រូវបានជ្រើសរើសពីប្រព័ន្ធ ចាប់ឆ្នោតរង្វង់ណាង។

រយៈពេលប្រូម៉ូសិន៖

ប្រូម៉ូសិននេះ ចាប់ផ្តើម ពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦ ("រយៈពេលប្រូម៉ូសិន") ឬបន្តទៅរយៈពេលផ្សេងទៀតដោយកំណត់តាមការសម្រេចចិត្តតែមួយគត់ និងដាច់ខាតរបស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ដោយមិនចាំបាច់ជូនដំណឹងជាមុន។

រយៈពេលប្រូម៉ូសិន	ការចំណាយដែលមានសិទ្ធិ	ប្រភេទកាត	អត្ថិភាពចូលរួម	ទីតាំង
ចាប់ពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០២៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦	២០ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ	អ៊ីអនកាតពណ៌ស្វាយ និងអ៊ីអនកាតពណ៌មាស	សិទ្ធិចូលរួម ១ ដង	គ្រប់បណ្តាហាងទាំងអស់ក្នុង ផ្សារទំនើបអ៊ីអនម៉លភ្នំពេញ អ៊ីអនម៉លសែនសុខ អ៊ីអនម៉លមានជ័យ និងអ៊ីអនខេមបូឌា គ្រប់សាខា

កាលវិភាគការចាប់រង្វាន់

ចំនួនបណ្តាសាច់ប្រាក់	ចំនួនអ្នកឈ្នះ	រយៈពេលប្រតិបត្តិការដែលមានសិទ្ធិចាប់រង្វាន់	កាលបរិច្ឆេទការចាប់រង្វាន់	ចាប់រង្វាន់តាមរយៈ
៥០០ ដុល្លារអាមេរិក ២៥០ ដុល្លារអាមេរិក ១០០ ដុល្លារអាមេរិក	៥០០ ដុល្លារអាមេរិក ចំនួន ២ នាក់ ២៥០ ដុល្លារអាមេរិក ចំនួន ៣ នាក់ ១០០ ដុល្លារអាមេរិក ចំនួន ១០ នាក់	ចាប់ពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០២៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦	សប្តាហ៍ទី២ នៃ ខែ មករា ឆ្នាំ២០២៧	ប្រព័ន្ធអេឡិចត្រូនិច របស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

Commented [HB1]: Please check the number of the winner.

Commented [SS2R1]: Done updated.

លក្ខខណ្ឌប្រូម៉ូសិន៖

- ចំណាយ ≥ 20ដុល្លារ ក្នុងមួយប្រតិបត្តិការ នឹងមានសិទ្ធិចូលរួមផ្សងរង្វាន់ចំនួន ០១ដង។
- ផ្តល់ជូនសម្រាប់ការធ្វើប្រតិបត្តិការដែលជោគជ័យ តាមរយៈអ៊ីអនកាត ឬ អ៊ីអនកាតម៉ូបាលស្តេនដើម្បីទូទាត់នៅក្នុងផ្សារទំនើបអ៊ីអនម៉លភ្នំពេញ អ៊ីអនម៉លសែនសុខស៊ីធី អ៊ីអនម៉លមានជ័យ អ៊ីអនខេមបូឌា គ្រប់សាខា។
- អតិថិជនអ៊ីអនកាតម្នាក់ មានសិទ្ធិឈ្នះរង្វាន់បានតែម្តងប៉ុណ្ណោះ។
- ការស្វែងរកអតិថិជនមានសំណាង នឹងធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ដែលប្រព្រឹត្តិឡើងនៅ សប្តាហ៍ទី២ នៃខែមករា ឆ្នាំ២០២៧ និងផ្សព្វផ្សាយ នៅគេហទំព័រផ្លូវការរបស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។
- បុគ្គលិករបស់ធនាគារឯកទេស អ៊ីអន និង បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនអ៊ីអនពុំមានសិទ្ធិចូលរួមក្នុងកម្មវិធីផ្សងសំណាងនេះឡើយ។
- ការផ្តល់ជូននេះមិនអាចប្តូរជាសាច់ប្រាក់ ឬទំនិញផ្សេងបានទេ។
- អតិថិជនដែលឈ្នះត្រូវឲ្យមកទទួលរង្វាន់តាមការជូនដំណឹងពី អ៊ីអន អេសភីប៊ី។ ប្រសិនបើមានអ្នកឈ្នះបដិសេធនូវរង្វាន់ ឬមិនអាចទំនាក់ទំនងបាន អ៊ីអន អេសភីប៊ី នឹងរក្សាសិទ្ធិក្នុងការផ្តល់រង្វាន់ឲ្យអ្នកឈ្នះថ្មី។
- ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរ ឬ កែប្រែ បញ្ជាក្តី និងលក្ខខណ្ឌប្រូម៉ូសិនដោយមិនចាំបាច់ជូនដំណឹងជាមុន។

ការដកសិទ្ធិ៖

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី រក្សាសិទ្ធិដាច់ខាតក្នុងការដកសិទ្ធិចូលរួមរបស់ម្ចាស់កាតដែលមានសិទ្ធិណាមួយ ដោយមិនចាំបាច់ជូនដំណឹងជាមុនក្នុងករណី៖

(ក) គណនីរបស់ម្ចាស់កាតដែលមានសិទ្ធិស្ថិតនៅក្នុងឈ្មោះ (ព័ត៌មានលម្អិតនៃ "ឈ្មោះ" សូមចុចលើតំណភ្ជាប់ (TCs-AEONCARD-EN & TCs-AEONCARD-KH)ក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(ខ) គណនីរបស់ម្ចាស់កាតដែលមានសិទ្ធិត្រូវបានបិទក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(ក) ម្ចាស់កាតដែលមានសិទ្ធិបានផ្តល់ព័ត៌មានមិនពិត ឬប្រព្រឹត្តបទល្មើសក្នុងរបៀបណាមួយក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(ឃ) ម្ចាស់កាតដែលមានសិទ្ធិរំលោភលើលក្ខខណ្ឌណាមួយដែលមានចែងនៅទីនេះ។

ការទទួលខុសត្រូវ៖

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី នឹងមិនទទួលខុសត្រូវចំពោះអ្នកចូលរួមណាមួយចំពោះការខូចខាតណាមួយដែលមានលក្ខណៈ ឬការខាតបង់ណាមួយដែលទទួលរង (រួមទាំងប៉ុន្តែមិនកំណត់ចំពោះការបាត់បង់ឆន្ទៈល្អ ប្រាក់ចំណូល ឬប្រាក់ចំណេញ ឬជាលទ្ធផល ដោយផ្ទាល់ ឬដោយប្រយោល ការបៃតង ផ្នែកទោស ឬការខូចខាតពិសេស) ទោះបីជាកើតឡើងទាក់ទងនឹងការចូលរួមក្នុងប្រូម៉ូសិន ឬ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី អនុវត្តសិទ្ធិរបស់ខ្លួនដោយអនុលោមតាមលក្ខខណ្ឌណាមួយនៅទីនេះ។

ជាទូទៅ៖

1) ការសម្រេចរបស់ អ៊ីអន អេសភីប៊ី លើរាល់បញ្ហាដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយនេះគឺចង និងជាចុងក្រោយ ហើយនឹងមិនមានការឆ្លើយឆ្លង ឬបណ្តឹងឧទ្ធរណ៍បន្ថែមទៀតទេ។ រាល់ក្ខខណ្ឌដែលមានចែងនៅទីនេះត្រូវបានគ្រប់គ្រងដោយ និងបកស្រាយដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់កម្ពុជា។
2) អ្នកចូលរួមទាំងអស់បានអាន និងយល់ពីរាល់លក្ខខណ្ឌដែលបានបញ្ជាក់នៅទីនេះ ហើយ អ៊ីអន អេសភីប៊ី មានសិទ្ធិដាច់មុខក្នុងការផ្អាក បញ្ចប់ ឬលុបចោលប្រូម៉ូសិននៅពេលណាមួយដោយគ្មានហេតុផល និងដោយមិនចាំបាច់ជូនដំណឹងជាមុនដូចដែលបានបញ្ជាក់នៅលើគេហទំព័រអ៊ីអន អេសភីប៊ី www.aeon.com.kh
3) សម្រាប់ការណែនាំ និង/ឬមតិយោបល់ពាក់ព័ន្ធនឹងប្រូម៉ូសិននេះ សូមទាក់ទងមកកាន់លេខទូរស័ព្ទទាន់ហេតុការណ៍របស់អ៊ីអន អេសភីប៊ី តាមរយៈទូរស័ព្ទទៅលេខ ០២៣/០៧០/០៧៨ ៩៨៨ ៥៥៥។